ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...១៤២៩.....អពដ

ថ្ងៃព្រហ. ១រោចខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៨

**សេចក្តីជូនដំណឹង**
**ស្តីពីការចុះផ្តល់សេវាពន្ធដារ**
**លើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ នៅរាជធានីភ្នំពេញ**

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតនៅក្នុងរាជធានីភ្នំពេញ មេត្តាជ្រាបថា ក្រុមការងារចម្រុះសម្រាប់ការងារចុះផ្តល់សេវាពន្ធដារ លើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ និងសាលារាជធានីភ្នំពេញ នឹងចាប់ផ្តើមចុះដល់ទីតាំងអចលនទ្រព្យរបស់ម្ចាស់អចលនទ្រព្យទាំងអស់ **ចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅ។**

ការចុះផ្តល់សេវាពន្ធដារ លើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនេះ ធ្វើឡើងដើម្បីស្រង់ស្ថិតិ, ថតរូបទីតាំង និងសាកសួរព័ត៌មានមួយចំនួនអំពីអចលនទ្រព្យដូចជា អត្តសញ្ញាណម្ចាស់អចលនទ្រព្យ, អត្តសញ្ញាណអចលនទ្រព្យ និងព័ត៌មានចាំបាច់ផ្សេងៗទៀត ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានអចលនទ្រព្យ ដែលបានចុះបញ្ជីនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ របស់អគ្គនាយកដ្ឋានពន្ធដារ។ ជាមួយគ្នានេះ ក្រុមការងារនឹងធ្វើការផ្សព្វផ្សាយពីបទប្បញ្ញត្តិស្តីពីពន្ធដារ, ការផ្តល់សេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ ព្រមទាំងសេវាពន្ធដារផ្សេងទៀត ជូនដល់ម្ចាស់អចលនទ្រព្យគ្រប់រូបឱ្យបានកាន់តែល្អប្រសើរ។

ដើម្បីបង្កភាពងាយស្រួល និងចៀសវាងការចំណាយពេលវេលា សូមម្ចាស់អចលនទ្រព្យទាំងអស់ មេត្តាត្រៀមលក្ខណៈជាមុន និងរៀបចំថតចម្លងទុកនូវឯកសារពាក់ព័ន្ធមួយចំនួន ជូនក្រុមការងារដូចខាងក្រោម÷

ក. <u>ករណីអចលនទ្រព្យ បានចុះបញ្ជីពន្ធដាររួចរាល់</u>

១. បង្កាន់ដៃបង់ពន្ធលើអចលនទ្រព្យ ឬ/និង

២. ប័ណ្ណសម្គាល់ការបង់ពន្ធអចលនទ្រព្យ (កាតសម្រាប់បង់ពន្ធអចលនទ្រព្យ)

ខ. <u>ករណីអចលនទ្រព្យ មិនទាន់បានចុះបញ្ជីពន្ធដារ</u>

១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

២. ប័ណ្ណសម្គាល់សិទ្ធិ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់ឡើងទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ម្ចាស់អចលនទ្រព្យទាំងអស់ នឹងចូលរួមផ្តល់ព័ត៌មាន និងជួយបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តការងារនេះ ដោយស្មារតីសហការ និងទទួលខុសត្រូវខ្ពស់ ដើម្បីទទួលបានសេវាពន្ធដារ លើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ បានត្រឹមត្រូវ និងច្បាស់លាស់ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ជាធរមាន។

សូមម្ចាស់អចលនទ្រព្យទាំងអស់ មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

Collection by VCAT Professional Consultant